# សុន្ទរកថា

## របស់ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
## ថ្លែងក្នុងពិធីប្រគល់វិញ្ញាបនបត្របញ្ជាក់សមត្ថភាពដល់
## គណៈកម្មការប្រឡងយកប័ណ្ណបើកបរ និងគ្រូបង្ហាត់បើកបរយានយន្ត

ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២

សូមគោរព៖

**-ឯកឧត្តម តូច ចាន់កុសល រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន**
**-ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការ ទីប្រឹក្សា អគ្គនាយក ប្រធាន-អនុប្រធាន នាយកដ្ឋាន ប្រធាន-អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត**
**-លោក លោកស្រី សមាជិក សមាជិកា នៃអង្គពិធីទាំងមូល ជាទីមេត្រី !**

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយដោយបានមកចូលរួមក្នុងពិធី " **ប្រគល់វិញ្ញាបនបត្របញ្ជាក់សមត្ថភាពដល់គណៈកម្មការប្រឡងយកប័ណ្ណបើកបរ និងគ្រូបង្ហាត់បើកបរយានយន្ត** " នាពេលនេះ ។ ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះសិក្ខាកាមទាំង ២៨៤ នាក់ ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ក្រោយពីបានខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ក្នុងការសិក្សារៀនសូត្រ រហូតទទួលបាននូវវិញ្ញាបនបត្រ នាថ្ងៃនេះ ។

ក្នុងនាមថ្នាក់ដឹកនាំក្រសួងសាធារណការ និងដឹកជញ្ជូន និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការកោតសរសើរ ចំពោះគណៈកម្មការប្រឡងយកវិញ្ញាបនបត្រ បញ្ជាក់សមត្ថភាពរបស់គ្រូបង្ហាត់បើកបរយានយន្ត និងគណៈកម្មការប្រឡងយកប័ណ្ណបើកបរយានយន្ត និងសិក្ខាកាមទាំងអស់ ដែលសម្រេចបានលទ្ធផលដ៏ល្អថ្លៃថ្លា លើគ្រប់ផ្នែកក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ស្របតាមភារកិច្ច និងតួនាទីរៀងៗខ្លួនក្នុងរយៈពេលកន្លងមក ។ លទ្ធផលដ៏ថ្លៃថ្លានេះ គឺពិតជាបានមកពីកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា និងសហការគ្នា ក្នុងការបង្រៀន និងការសិក្សាស្រាវជ្រាវ ទោះបីជានៅមានការលំបាកខ្លះយ៉ាងណាក៏ដោយ ។ ខ្ញុំយល់ថា សមិទ្ធផលដែលគណៈកម្មការប្រឡងយកវិញ្ញាបនបត្របញ្ជាក់សមត្ថភាពរបស់គ្រូបង្ហាត់បើកបរយានយន្ត និងគណៈកម្មការប្រឡងយកប័ណ្ណបើកបរយានយន្ត និងសិក្ខាកាមទាំងអស់ទទួលបានថ្ងៃនេះ គឺជាការឆ្លុះបញ្ចាំងនូវផ្លែផ្កាដ៏ត្រចះត្រចង់ នៃការអបអរសាទរផែនការសកម្មភាពជាតិទសវត្សរ៍សុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ២០១១-២០២០ តាមរយៈការចូលរួមកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក នៅព្រះរាជាណាចក្រកម្ពុជា ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូល ជាទីមេត្រី !*

យើងទាំងអស់គ្នាបានដឹងហើយថា នៅទូទាំងប្រទេសនាពេលបច្ចុប្បន្ននេះ កំណើនយានយន្តគ្រប់ប្រភេទមានការកើនឡើងជារៀងរាល់ឆ្នាំ ។ ជាក់ស្តែងតាមស្ថិតិយានយន្តដែលបានចុះបញ្ជីមកដល់ឆ្នាំ២០១១កន្លងទៅនេះ មានចំនួនជិត ២លានគ្រឿង ទន្ទឹមនឹងនេះចំនួនអ្នកបើកបរក៏មានការកើនឡើងដែរ ។ ប៉ុន្តែជាការគួរឲ្យសោកស្តាយ គ្រោះថ្នាក់ចរាចរណ៍ក៏មានការកើនឡើងទាំងបរិមាណ និងទិដ្ឋភាពយ៉ាងរន្ធត់គួរឲ្យព្រួយបារម្ភ ។ ក្នុងរយៈពេលប្រាំមួយឆ្នាំកន្លងទៅនេះគឺពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១១ ចំនួនអ្នកស្លាប់បានកើនឡើងជាង៥០% នៅពេលដែលចំនួនប្រជាពលរដ្ឋសរុបបានកើនឡើងជាង៦% ហើយចំនួនយានយន្តចុះបញ្ជីបានកើនឡើង ១៣០% ។ ភាគច្រើននៃគ្រោះថ្នាក់ចរាចរណ៍គឺ បណ្តាលមកពីកត្តាមនុស្សមានរហូតដល់ ៩៥% ដែលក្នុងនោះគ្រោះថ្នាក់ដែលបង្កឡើងដោយសារការបើកបរហួសល្បឿនកំណត់មាន ៥១% បើកបរក្រោមឥទ្ធិពលជាតិស្រវឹងមាន ១៦% និងកត្តាផ្សេងៗទៀត ។

ដើម្បីឆ្លើយតបទៅនឹងស្ថានភាពគ្រោះថ្នាក់ចរាចរណ៍នាពេលបច្ចុប្បន្ននេះ ក៏ដូចជាការអនុវត្តផែនការសកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដំណាក់កាលទី២ ស្តីពីទស្សវត្សរ៍សុវត្ថិភាពចរាចរណ៍ផ្លូវគោក ក្រសួងសាធារណការ និងដឹកជញ្ជូន បានបើកវគ្គបណ្តុះបណ្តាល និងប្រឡងយកវិញ្ញាបនប័ត្របញ្ជាក់សមត្ថភាពដល់គ្រូបង្ហាត់បើកបរយានយន្ត និងគណៈកម្មការប្រឡងយកប័ណ្ណបើកបរយានយន្តនៅទូទាំងប្រទេស ចាប់ពីឆ្នាំ២០០៩ រហូតដល់ឆ្នាំ២០១១ កន្លងទៅនេះ ។ ជាលទ្ធផល យើងសម្រេចបានជោគជ័យ ដោយបានបើកវគ្គបណ្តុះបណ្តាល និងប្រឡងយកវិញ្ញាបនប័ត្របញ្ជាក់សមត្ថភាព ដល់គ្រូបង្ហាត់បើកបរយានយន្ត០៥វគ្គ បានចំនួន ២៧៦នាក់ និងគណៈកម្មការប្រឡងយកប័ណ្ណបើកបរយានយន្ត០៣វគ្គ បានចំនួន២០៧នាក់។ ការបើកវគ្គបណ្តុះបណ្តាលខាងលើ បង្ហាញឲ្យឃើញនូវយុទ្ធសាស្ត្រយន្តការ នៃការអភិវឌ្ឍធនធានមនុស្សប្រកបដោយថាមពល សំដៅរួមចំណែកកាត់បន្ថយចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ឲ្យមានប្រសិទ្ធិភាពស្របតាមការវិវត្តន៍ នៃស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ និងស្របតាមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ដែលបានកំណត់កាត់បន្ថយចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ឲ្យបាន ៥០% នៅឆ្នាំ២០២០។ ពិតណាស់ថា ការបណ្តុះបណ្តាលឲ្យអ្នកបើកបរមានសមត្ថភាព បើកបរដោយសុវត្ថិភាព មានសីលធម៌ក្នុងការបើកបរ គឺត្រូវពឹងអាស្រ័យជាចម្បងទៅលើសមត្ថភាពរបស់គ្រូបង្ហាត់បើកបរយានយន្ត។ពីព្រោះថា គ្រូបង្ហាត់បើកបរយានយន្ត គឺជាអ្នកបណ្តុះនូវគំនិតបញ្ញាបែបប្រឌិតញាណ ពោលគឺជាពុទ្ធិ ដែលកើតចេញពីការសិក្សារៀនសូត្រ រៀនគិត រៀនធ្វើ រៀនដកស្រង់ពិសោធន៍ និងរៀនត្រិះរិះពិចារណាប្រកបដោយគតិបណ្ឌិត និងវិចារណញ្ញាណ ។ ទន្ទឹមនឹងនោះ គ្រូបង្ហាត់បើកបរយានយន្ត ត្រូវ

យកចិត្តទុកដាក់ឲ្យបានមុតមាំនូវការបំពាក់បំប៉ន ជូនដល់សិស្សរបស់យើងទាំងចំណេះដឹងផ្នែកទ្រឹស្តី និងការអនុវត្តដែចង្កូត លើសពីនេះទៀត ត្រូវយកចិត្តទុកដាក់ឲ្យបានជាអតិបរមាផងដែរ ចំពោះគោលការណ៍នៃការគោរពច្បាប់ សណ្តាប់ធ្នាប់ សីលធម៌ និងសុជីវធម៌ក្នុងការបើកបរ ដើម្បីឲ្យសិស្សទាំងអស់ក្លាយខ្លួនទៅជាអ្នកបើកបរមានសមត្ថភាព បើកបរដោយសុវត្ថិភាព ក្រោយពេលដែលអ្នកទាំងនោះបានបញ្ចប់ការសិក្សាដោយជោគជ័យ ។

ប្រការខាងលើនេះ គឺបញ្ជាក់អះអាងថា ការបើកបរប្រកបដោយសុវត្ថិភាព បានរួមចំណែកយ៉ាងសំខាន់ក្នុងការទប់ស្កាត់ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ដែលរាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ និងផ្តល់អទិភាពខ្ពស់តាមរយៈការដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ វិធានការនានា ដើម្បីកាត់បន្ថយចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ឲ្យមកកម្រិតទាបបំផុត ។ ក្នុងស្មារតីនេះ ដើម្បីពង្រឹងគុណភាពដល់អ្នកបើកបរ ខ្ញុំសូមមានមតិផ្តាំផ្ញើមួយចំនួន ចំពោះគណៈកម្មការប្រឡងយកប័ណ្ណបើកបរយានយន្ត គ្រូបង្ហាត់បើកបរយានយន្ត និងសាលាបង្រៀនបើកបរយានយន្ត ដូចខាងក្រោម ៖

១-លោក លោកស្រី ដែលជាគណៈកម្មការប្រឡងយកប័ណ្ណបើកបរយានយន្តរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្តទាំងអស់ ត្រូវខិតខំប្រឹងប្រែងបន្តទៀតក្នុងការពង្រឹងគុណភាព និងតម្លាភាពលើការប្រឡងយកប័ណ្ណបើកបរយានយន្តគ្រប់ប្រភេទ ។

២-លោកគ្រូ អ្នកគ្រូបង្ហាត់បើកបរយានយន្តទាំងអស់ ត្រូវយកចិត្តទុកដាក់ឲ្យបានមុតមាំនូវការបំពាក់បំប៉នជូនសិស្សរបស់យើង ទាំងចំណេះដឹងផ្នែកទ្រឹស្តី និងការអនុវត្តដៃចង្កូត លើសពីនេះទៀត ត្រូវយកចិត្តទុកដាក់ឲ្យបានជាអតិបរមាផងដែរ ចំពោះគោលការណ៍នៃការគោរពច្បាប់ សណ្តាប់ធ្នាប់ សីលធម៌ និងសុជីវធម៌ក្នុងការបើកបរ ដើម្បីឲ្យសិស្សទាំងអស់ក្លាយខ្លួនទៅជាអ្នកបើកបរមានសមត្ថភាព បើកបរដោយសុវត្ថិភាព ក្រោយពេលដែលអ្នកទាំងនោះបានបញ្ចប់ការសិក្សាដោយជោគជ័យ ។

៣-សាលាបង្រៀនបើកបរត្រូវបន្តធ្វើវិត្ថារកម្មសាលារបស់ខ្លួន តាមលទ្ធភាពជាក់ស្តែង ក្នុងនោះត្រូវយកចិត្តទុកដាក់ខ្ពស់ ផ្តោតលើការពង្រឹងគុណភាពនៃការបង្រៀន ដោយអនុវត្តតាមប្រកាសស្តីពី ការគ្រប់គ្រងការធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្ត របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ធានា ដល់ការអប់រំ បណ្តុះបណ្តាល អ្នកបើកបរប្រកបដោយគុណភាព និងចិរភាព ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូល ជាទីមេត្រី !*

ថ្ងៃនេះ ខ្ញុំអាចនិយាយបានថា ជាថ្ងៃប្រវត្តិសាស្ត្រប្រចាំជីវិតរបស់លោកគ្រូ អ្នកគ្រូបង្ហាត់បើកបរយានយន្ត និងលោក លោកស្រីដែលជាគណៈកម្មការប្រឡងយកប័ណ្ណបើកបរយានយន្ត ដែលបានទន្ទឹងរង់ចាំជាយូរមកហើយ ពីព្រោះជាថ្ងៃត្រូវទទួលវិញ្ញាបនបត្របញ្ចប់ការបណ្តុះបណ្តាល ។ សម្រាប់លោក លោកស្រី ដែលទទួលបានវិញ្ញាបនបត្រ នាពេលនេះ ខ្ញុំសូមកោតសរសើរចំពោះកិច្ចខិតខំព្យាយាមរៀនសូត្ររបស់លោក លោកស្រី រហូតបានប្រឡងជាប់ដោយជោគជ័យ ។ ជាមួយនេះតទៅមុខទៀត លោក លោកស្រី ត្រូវតែខិតខំថែមទៀត ដើម្បីថែបំប៉ន និងលើកកម្ពស់សមត្ថភាពរបស់ខ្លួនឲ្យបានជាប្រចាំ ទាំងខាងចំណេះដឹង ចំណេះធ្វើ និងសីលធម៌ សម្រាប់យកទៅប្រើប្រាស់ឲ្យបានជាគុណប្រយោជន៍ដល់ខ្លួនឯងផង ដល់គ្រួសារផង និងដល់សង្គមជាតិផង ។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះគណៈកម្មការប្រឡងយកវិញ្ញាបនបត្របញ្ជាក់សមត្ថភាពរបស់គ្រូបង្ហាត់បើកបរយានយន្ត និងគណៈកម្មការប្រឡងយកប័ណ្ណបើកបរយានយន្ត ដែលបានខិតខំសម្រេចបានជោគជ័យដ៏ថ្លៃថ្លាក្នុងវគ្គបណ្តុះបណ្តាល និងប្រឡងយកវិញ្ញាបនបត្របញ្ជាក់សមត្ថភាពដល់គ្រូបង្ហាត់បើកបរយានយន្ត និងគណៈកម្មការប្រឡងយកប័ណ្ណបើកបរយានយន្ត នាពេលនេះ ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមបានប្រកបដោយពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

**សូមអរគុណ !**